# មេរៀនទី ១០៧: ព្រះមេស្ស៊ីប្រសូតហើយ

## លូកា ២:១-២០; ហេព្រើរ ១:១-៤

**គោលបំណង៖** ព្រះយេស៊ូវប្រសូត។

**ខគម្ពីរចងចាំ៖ លូកា ២:១១** *"ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ១អង្គ ប្រសូតដល់អ្នករាល់គ្នា នៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវគឺជាអំណោយ និងតែងតែជាអំណោយបុណ្យណូអែលដ៏ល្អបំផុតដែលមិនធ្លាប់មាន! សូមអានព្រះគម្ពីរ **ហេព្រើរ ១:១-៤**ឡើងវិញ ជាវិធីមួយដើម្បីអបអរសាទរការពិតនៃបុណ្យណូអែល។ មិនថាអ្នកគិតយ៉ាងណាអំពីបុណ្យណូអែល នៅពេលដែលអ្នកផ្តោតអារម្មណ៍លើព្រះយេស៊ូវ វានឹងក្លាយជាថ្ងៃឈប់សម្រាកដ៏ល្អបំផុតដែលមិនធ្លាប់មាន។ តើបុណ្យណូអែលគឺជាពេលវេលាដ៏រីករាយសម្រាប់អ្នកឬទេ? វត្តមានរបស់ព្រះយេស៊ូវអាចធ្វើឲ្យអ្នកកាន់តែរីករាយ។ តើបុណ្យណូអែលគឺជាពេលវេលាដ៏សោកសៅសម្រាប់អ្នកឬ? ព្រះយេស៊ូវអាចបំពេញចន្លោះ ដែលអ្នកមានអារម្មណ៍ថាខ្វះខាតនៃឆ្នាំនេះបាន។

**ចំរៀង៖** ១. យប់ដ៏សុខសាន្ត ២. ទ៏ព្វពួកទេវច្រៀងបទ ៣. អបអរសាទរ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ឱបប៉េងប៉ោង»**



***សម្ភារៈដែលត្រូវការ៖*** ប៉េងប៉ោង និងកៅអី

១. ចែកកុមារជា ២ក្រុម

២. ដាក់កៅអីនៅចុងម្ខាងទៀតនៃថ្នាក់រៀន

៣. ឲ្យប៉េងប៉ោង ៣ ទៅកុមារគ្រប់ៗគ្នា ដោយពួកគេត្រូវដាក់ប៉េងប៉ោងនៅគៀបក្រោមក្លៀកសងខាង និងមួយដាក់នៅចន្លោះជើង។

៤. ពួកគេត្រូវព្យាយាមដើរដោយគៀបប៉េងប៉ោងនោះ ទៅឲ្យដល់ចុងថ្នាក់រៀន ហើយប្រគល់វាឲ្យគ្រូ។

៥. ប្រសិនបើកុមារណាធ្វើឲ្យប៉េងប៉ោងជ្រុះនោះពួកគេមិនអាចរើសវាបានទេ ហើយគេនឹងចាញ់ល្បែងនេះ។

៦. ក្រុមណាដែលអាចជញ្ជូនប៉េងប៉ោងទៅដល់ចុងម្ខាងនៃថ្នាក់រៀនបានច្រើនជាងគេ ក្រុមនោះជាអ្នកឈ្នះ។

៧. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាមិនងាយស្រួលនោះទេក្នុងការដើរដោយមានប៉េងប៉ោង៣នោះ។ នៅពេលដែលម៉ារាពពោះព្រះយេស៊ូវ វាគឺពិតជាមានការពិបាកណាស់ក្នុងការដេក ដើរ ឈរ អង្គុយក្នុងការ

ធ្វើការប្រចាំថ្ងៃ។ ប៉ុន្តែគាត់បានផ្ដល់កំណើតដល់ព្រះយេស៊ូវ ពីព្រោះទ្រង់ជាព្រះអង្គសង្គ្រោះរបស់យើងរាល់គ្នា។

## ៤. ការណែនាំមេរៀន

ថ្ងៃនេះយើងធ្វើការអបអរសាទរដល់ការប្រសូត្រមករបស់ព្រះយេស៊ូវ ពីព្រោះថាជិតដល់ថ្ងៃបុណ្យណូអែលហើយ។ ព្រះយេស៊ូវបានយាងមកផែនដីនេះគឺ ដោយព្រោះព្រះទ្រង់បានស្រលាញ់មនុស្សលោកជាខ្លាំង ដូច្នេះហើយទើបទ្រង់បានចាត់ព្រះយេស៊ូវមក ដើម្បីបង្ហាញដល់មនុស្សគ្រប់គ្នាក្នុងលោកីយ៍នេះឱ្យបានដឹងថា តើព្រះគឺជានរណា។ ថ្ងៃនេះពួកយើងមកទីនេះដើម្បីអបអរសាទរពីសេចក្តីស្រលាញ់ និងការប្រសូត្រមករបស់ព្រះយេស៊ូវ។ វាគឺជាការសំខាន់ណាស់ក្នុងការចងចាំថាថ្ងៃបុណ្យណូអែលប្រារព្ធធ្វើឡើង ដើម្បីអបអរដល់ការប្រសូត្ររបស់ចព្រះយេស៊ូវ-គ្រីស្ទ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ម៉ារា និងយ៉ូសែបគឺរស់នៅណាសារ៉ែត ស្រុកកាលីឡេ។ ប៉ុន្តែស្តេចសេសារ-អូគូស្ទ បានចេញព្រះរាជឱង្ការមួយច្បាប់ឲ្យមនុស្សទាំងអស់ដែលនៅដែនដីរ៉ូមបានចុះបញ្ជី។ នៅគ្រានោះពួកអ៊ីស្រាអែលត្រូវបានគ្រប់គ្រងដោយចក្រភពរ៉ូម។ នេះគឺមានន័យថា ប្រជាជនទាំងអស់ត្រូវតែធ្វើដំណើរទៅស្រុកកំណើតខ្លួនដើម្បីចុះបញ្ជី។ នេះគឺមានន័យថា ម៉ារា និងយ៉ូសែបត្រូវធ្វើដំណើរទៅបេថ្លេហិម ក្រុងរបស់ហ្លួងដាវីឌ ពីព្រោះពួកគាត់ទាំងពីរជាព្រះវង្សហើយជាព្រះញាតិនឹងហ្លួងដាវីឌដែរ។

ការធ្វើដំណើរនេះមិនងាយស្រួលនោះទេសម្រាប់ម៉ារា និងយ៉ូសែប ដោយសារតែម៉ារាមានទម្ងន់។ នៅពេលដែលពួកគេបានធ្វើដំណើរទៅដល់បេថ្លេហិម ព្រះយេស៊ូវក៏បានប្រសូត្រនៅក្នុងក្រោលសត្វ និងបានដាក់ទ្រង់ផ្ទំក្នុងស្នូកឈើ ដែលគេប្រើសម្រាប់ដាក់ចំណីឲ្យសត្វស៊ី។ នេះដោយសារតែមិនមានបន្ទប់ជួលសម្រាប់ពួកគេ។ ព្រះយេស៊ូវគឺជាស្តេចលើស្តេច និងជាព្រះលើព្រះ ប៉ុន្តែទ្រង់បានប្រសូត្រនៅក្នុងកន្លែងដ៏តូចទាបបំផុត។ ព្រះទ្រង់បានប្រទានព្រះរាបុត្រាតែមួយ គឺព្រះយេស៊ូវមកកាន់លោកីយ៍នេះសម្រាប់យើងរាល់គ្នា។ ព្រះយេស៊ូវប្រសូត្រមកដើម្បីសង្គ្រោះអ្នក ដើម្បីផ្តល់ជីវិតដល់អ្នក និងដើម្បីជួយដល់អ្នក។ ប៉ុន្តែទ្រង់មិនបានរើសយកការប្រសូត្រនៅក្នុងរាជវាំង ឬក៏នៅក្នុងប្រាសាទនោះទេ។ ទ្រង់បានប្រសូត្រនៅកន្លែងដែលនៅជិតមនុស្សម្នាបំផុត។

តាមពិតក្រុមមនុស្សដំបូងដែលបានរៀនអំពីកំណើតរបស់ព្រះយេស៊ូវ ដែលជាព្រះមេស្ស៊ីគឺជាអ្នកគង្វាលចៀម។ ក្នុងអំឡុងពេលនោះអ្នកគង្វាលមិនមែនជាមនុស្សសំខាន់ទេ។ ប៉ុន្តែមានទេវតាមួយរូបមកពីព្រះបានលេចមកឲ្យអ្នកគង្វាល ដែលជាមនុស្សថ្នាក់ទាបដើម្បីប្រាប់ពួកគេអំពីព្រះយេស៊ូវ។

ព្រះមិនបានខ្វល់ថាអ្នកមាន ឬអ្នកក្រប៉ុនណានោះទេ។ ទ្រង់តែងតែរកមើលអស់អ្នកដែលបន្ទាបខ្លួន អ្នកដែលត្រូវការទ្រង់នៅក្នុងជីវិតរស់នៅរបស់ពួកគេ។ តើអ្នកត្រូវការព្រះនៅក្នុងជីវិតរស់នៅរបស់អ្នកដែរឬទេ? តើអ្នកចង់មានព្រះវត្តមានរបស់ព្រះនៅក្នុងជីវិតរបស់អ្នកដែរឬទេ? ដូច្នេះចូរអរសប្បាយចុះ ពីព្រោះព្រះយេស៊ូវបានប្រសូត្រហើយ! ទ្រង់យាងមកដើម្បីសង្គ្រោះអ្នក និងជួយដល់អ្នក! ចូរយើងអបអរសាទរការប្រសូតរបស់ព្រះយេស៊ូវ ក្នុងថ្ងៃបុណ្យណូអែលនេះ!

## ៦. សំនួរពិភាក្សា

១. តើម៉ារានិងយ៉ូសែបត្រូវទៅចុះបញ្ជីនៅឯណា? *បេថ្លេហិម*

២. តើព្រះយេស៊ូវបានប្រសូត្រនៅឯណា? *ព្រះយេស៊ូវបានប្រសូត្រនៅក្នុងក្រោលសត្វ និងបានដាក់ទ្រង់ផ្ទុំក្នុងស្នូក នេះដោយសារតែមិនមានបន្ទប់ជួលសម្រាប់ពួកគេ*

៣. ហេតុអ្វីបានជាព្រះចាត់ទេវតាឲ្យទៅប្រាប់អ្នកគង្វាលចៀមពីដំណឹងល្អ អំពីការប្រសូតរបស់ព្រះយេស៊ូវ ជំនួសឲ្យការទៅប្រាប់ដល់ស្តេច ឬអ្នកដឹកនាំសាសនានោះ?
*ដោយសារពួកអ្នកគង្វាលមានចិត្តរាបទាប ហើយដឹងថាពួកគេត្រូវការព្រះយេស៊ូវ*

៤. តើអ្នកអាចអបអរសាទរចំពោះថ្ងៃកំណើតរបស់ព្រះយេស៊ូវបានដោយរបៀបណា?
*ទុកឲ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «ការបញ្ជូនប៉េងប៉ោង»

**សម្ភារៈដែលត្រូវការ៖** ប៉េងប៉ោង



១. ចែកកុមារជា២ ឬ៣ក្រុម

២. ឲ្យកុមារម្នាក់មកពីគ្រប់ក្រុមឈរនៅចុងម្ខាងនៃថ្នាក់រៀន ដើម្បីកាន់ប៉េងប៉ោងសម្រាប់ក្រុមរបស់ពួកគេ។



៣. ឲ្យកុមារទី១ គ្រប់ក្រុមរត់ទៅចុងម្ខាងនៃថ្នាក់រៀន ដើម្បីយកប៉េងប៉ោងមួយពីអ្នកឈរកាន់ប៉េងប៉ោង។ បន្ទាប់មកពួកគេត្រូវរត់ត្រលប់មកកាន់សមាជិកក្រុមរបស់ខ្លួនវិញ រួចដាក់ប៉េងប៉ោងនៅចន្លោះខ្នងដែលទល់នឹងទ្រូងរបស់ដៃគូរ ហើយរត់ទៅយកប៉េងប៉ោងមួយទៀត។ បន្តលេងល្បែងនេះរហូត ដល់សមាជិកក្រុមបានលេងទាំងអស់គ្នា។



៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាមិនមែនជាការងាយស្រួលសម្រាប់ព្រះយេស៊ូវ ដែលបានប្រសូត្រមកក្នុងលោកីយ៍នេះទេ ប៉ុន្តែតាមរយៈការជួយរបស់មនុស្សជាច្រើន ការប្រសូត្ររបស់ទ្រង់ក៏ត្រូវបានគេអបអរសាទរឡើង។

## ៨. ខគម្ពីរចងចាំ លូកា ២:១១

## ៩. ហត្ថកម្ម « អំណរដល់លោក ព្រះបុត្រប្រសូត »

**សម្ភារៈដែលត្រូវការ៖** ព្រីនក្រដាសហត្ថកម្ម(ខាងក្រោម) កូល័រ កន្ត្រៃ និងការបិត

១.ឲ្យកុមារផាត់ពណ៌ក្រដាសហត្ថកម្មនោះ។

២. ឲ្យកុមារកាត់តាមបន្ទាត់ដិតពណ៌ខ្មៅ ហើយបត់តាមបន្ទាត់ដាច់ៗ ហើយបិតវាធ្វើជាស្រោមសំបុត្រ។

៣.បិតក្រដាសដែលសរសេរថា “អំណរដល់លោក ព្រះបុត្រប្រសូត្រ”
នៅពីមុខស្រោមសំបុត្រ។

៤.បិតរូបផ្កាយនៅផ្នែកខាងលើបំផុតនៃស្រោមសំបុត្រ។

៥. ដាក់រូបព្រះបុត្រយេស៊ូវនៅក្នុងសំបុត្រនោះ ហើយព្យួរវានៅកន្លែងណាក៏បាននៅក្នុងផ្ទះ ដើម្បីរំលឹកពួកយើងថា ព្រះយេស៊ូវប្រសូត្រមកដើម្បីសង្គ្រោះ និងជួយដល់ពួកយើង!




**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# អំណរដល់លោកព្រះបុត្រប្រសូត្រ











